ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៩ លេខ ០៦

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



Work Activities

ប្រចាំខែមិថុនា ឆ្នាំ២០១៦



# មាតិកា


ល.រ បរិយាយ លេខទំព័រ

I- កិច្ចប្រជុំជំនាញបច្ចេកទេស

១- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍសិល្បៈជាតិ ១-២

២- សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ ៣-៤

II- កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៦ ៥-១៣

III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១៦ ១៤-១៩

# ១- សេចក្តីព្រាងអនុក្រឹត្យស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ នៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍសិល្បៈជាតិ

កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍសិល្បៈជាតិ** ដោយមានការអញ្ជើញចូលរួមពី សមាជិក និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

ពិនិត្យលើទិដ្ឋភាពជាក់ស្តែង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មឲ្យដឹកនាំ និងគ្រប់គ្រងវិស័យវប្បធម៌ និងវិចិត្រសិល្បៈនៃព្រះរាជាណាចក្រកម្ពុជា និងមានសមត្ថកិច្ចថែរក្សា លើកតម្កើងតម្លៃវប្បធម៌ ជំនឿ ទំនៀមទម្លាប់ ប្រពៃណីរបស់ជាតិ តាមរយៈការបំផុសឲ្យមានការបង្កើតស្នាដៃសិល្បៈវប្បធម៌ ការផ្សព្វផ្សាយ និងការអភិវឌ្ឍសកម្មភាពវប្បធម៌។

នៅក្នុងបរិបទនៃសម័យសាកលភាវូបនីយកម្ម ទប់ស្កាត់នូវការហូរចូលដោយគំហុកនូវវប្បធម៌អវិជ្ជមានពីបរទេស រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌ កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤ កន្លងទៅ ដើម្បីជាមូលដ្ឋានគ្រឹះ និងជាត្រីវិស័យក្នុងការនាំឆ្ពោះទៅដល់ការផ្សារភ្ជាប់វិស័យវប្បធម៌ទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការពង្រឹងអត្តសញ្ញាណជាតិ ការលើកស្ទួយសីលធម៌ និងកិត្យានុភាពជាតិ ការរក្សាការពារចំណេះដឹងប្រពៃណី និងការលើកស្ទួយភាពផ្សេងគ្នានៃវប្បធម៌។

ដោយពិនិត្យនូវភាពចាំបាច់ក្នុងការធានាសុវត្ថិភាព សុខដុមភាព និរន្តរភាពនិងវឌ្ឍនភាពវប្បធម៌ជាតិក្នុងការលើកកម្ពស់សីលធម៌ គុណធម៌ ប្រពៃណីជាតិ ពង្រឹងអត្តសញ្ញាណ និងកិត្យានុភាពជាតិ និងអនុលោមតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៤ ក្រសួងវប្បធម៌ និង

វិចិត្រសិល្បៈ ក្រោមកិច្ចសម្របសម្រួលពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍសិល្បៈជាតិនេះ[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍសិល្បៈជាតិ ។

# ២- សេចក្តីព្រាងអនុក្រឹត្យស្តីពី

## ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីអធិការកិច្ចការងារ

កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុភ ផេខ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ** ដោយមានការអញ្ជើញចូលរួមពី សមាជិក និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។




កន្លងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំឯកសណ្ឋានសម្រាប់មន្ត្រីអធិការកិច្ចការងារអនុវត្តការងារប្រចាំថ្ងៃ តាមរយៈប្រកាសលេខ០៣៦/១៤កប/ប្រក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤។ ដូចនេះ ដើម្បីឲ្យមានការទទួលស្គាល់នូវអត្តសញ្ញាណមន្ត្រីអធិការកិច្ចការងារ ក្នុងកម្រិតថ្នាក់ជាតិ ក្រសួងបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ សម្រាប់ប្រើប្រាស់ដូចជា ការបំពេញការងារប្រចាំថ្ងៃ បេសកកម្មពាក់ព័ន្ធនឹងការងារអធិការកិច្ចការងារ និងពង្រឹងការអនុវត្តច្បាប់ក្នុងប្រតិបត្តិការស្រាវជ្រាវ ទប់ស្កាត់ ដោះស្រាយវិវាទការងារ និងកូដកម្ម បាតុកម្មគ្រប់មុខសញ្ញា ពិធីបុណ្យទិវាពលកម្មអន្តរជាតិ ១ឧសភា ពិធីប្រជុំផ្លូវការផ្សេងៗ និងសវនាការតុលាការការងារ និងតុលាការអាជ្ញាកណ្តាល។ សេចក្តីព្រាងអនុក្រឹត្យនេះត្រូវបានរៀបចំឡើងជាជំពូក និងមាត្រា ដែលរួមមាន ៧ជំពូក និង១១មាត្រា[១]។




អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ ។

## II- កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៦ *



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ **ប្រចាំខែឧសភា ឆ្នាំ២០១៦**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

### ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែឧសភាឆ្នាំ២០១៦សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៤%ធៀបនឹងខែមុន និងកើនឡើង៣,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ម្ហូបអាហារ: | +៦,១% | សាច់ជ្រូក: | +៣,២% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +១០,៩% | សាច់គោ: | +១០,៥% |
| សំលៀកបំពាក់ និងស្បែកជើង : | +៥,៨% | សាច់មាន់: | +៦,៧% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់ : | +៣,០% | ត្រីស្រស់: | +១០,២% |
| សុខាភិបាល | +៣,១% | ផ្លែឈើ: | +៥,៥% |
| ភោជនីយដ្ឋាន: | +៥,៧% | បន្លែ: | +១០,៣% |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៤–២០១៦

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មេសា | ឧសភា | ឧសភា | មិថុនា P | កក្កដា P | សីហា P | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,២% | ៣,១% | ៣,១% | | | | | |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៤ | ០,៣% | ០,៥% | ០,៣% | | | | | |
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |
| | មុន | -០,៤% | ១,២% | ០,១% | ០,៧% | ០,១% | ០,២% | ០,៦% | ០,៣% | ០,២% | ០% | -០,២% | ០,២% | |
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤,៥% | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | ៤,២% | ៤,១% | ៣,៦% | ២,៩% | ២,៤% | ២,៥% | ៣,៩% |
| | មុន | ០,២% | ០ | ០,៥% | ០,៥% | ០,៣% | ០,៥% | ០,៤% | ០,៣% | ០,២% | -០,៤% | -០,៨% | ០,៧% | |

**P**: តួលេខខែមិថុនា កក្កដា និងសីហា ឆ្នាំ២០១៦ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្រប់ដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | ឧសភា២០១៦ | មេសា២០១៦ | ឧសភា២០១៥ | *ប្រភេទ* | ឧសភា២០១៦ | មេសា២០១៦ | ឧសភា២០១៥ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៨៥៛/១$ | ៤០៦០៛/១$ | ៤០៦៨៛/១$ | **បាត/ដុល្លារ** | ៣៥,៧២បាត/១$ | ៣៤,៩៩បាត/១$ | ៣៣,៧៦បាត/១$ |
| **៛/បាត** | ១១៤៛/១បាត | ១១៦៛/១បាត | ១២០៛/១បាត | **ដុង/ដុល្លារ** | ២២៤១៥ដុង/១$ | ២២២៧៨ដុង/១$ | ២១៧៨៥ដុង/១$ |
| **៛/ដុង** | ០,១៨២៛/១ដុង | ០,១៨២៛/១ដុង | ០,១៨៧៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែឧសភាឆ្នាំ ២០១៦ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១៣៦០,៤ ប៊ីលានរៀល( *មធ្យមប្រចាំខែ ១០៨% នៃផែនការ*) ក្នុងនោះ: ចំណូលចរន្តចំនួន១៣៥៤,៦ ប៊ីលានរៀល( *មធ្យមប្រចាំខែ ១១០% នៃផែនការ*) និងចំណូលមូលធន ចំនួន ៥,៨ ប៊ីលានរៀល (តាមតួលេខ រតនាគារជាតិ)។

➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិកើនឡើង៤,៤% និង កើនឡើង៣៤,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១០៩៨,២ប៊ីលានរៀល ថយចុះ១០,២%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៤-២០១៦ (ប៊ីលានរៀល)




✓ចំណូលមិនមែនសារពើពន្ធ មានចំនួន២៥៦,៤ប៊ីលានរៀល កើនឡើង២១៩,៩% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១០១,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ រតនាគារជាតិ)។

តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

| ចំណូលសារពើពន្ធ (ក្នុងរង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ចំណូលមិនមែនសារពើពន្ធ (តាមតួលេខ រតនាគារជាតិ) (ក្នុងរង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: +១,០% | (+១០,២%) | ➢កាស៊ីណូ: +៥៧,៣% | (+៨៥,៣%) |
| (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | | ➢អាជ្ញាបណ្ណក្នុងស្រុក : +៤១៧៥,៣% | (+១១,៤%) |
| ➢ *ចំណូលពន្ធដារ:* -៣៤,៥% | (+៤២,០%) | ➢ នេសាទ:+៣៣៥,៥% | (+៦១,១%) |
| (អគ្គនាយកដ្ឋានពន្ធដារ) | | ➢សម្បទានរ៉ែ: +៥៨៥,៧% | (+៤៤៨,៨%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: +២៧៦,២% | (-១១,២%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: +៩០២០,៩% | (+១០៥,៥%) |
| | | ➢អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ): +១១៨,៦% | (+៣៥,៦%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ៨៨៨,៥ប៊ីលានរៀល(*មធ្យមប្រចាំខែ ៦៦% នៃផែនការ*) ក្នុងនោះ ចំណាយចរន្ត ចំនួន៧៧៥,២ ប៊ីលានរៀល (*មធ្យមប្រចាំខែ ៦៧% នៃផែនការ*) និងចំណាយមូលធនមានចំនួន ១១៣,៣ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិកើនឡើង១៧,២%ធៀបនឹងខែមុននិងកើនឡើង៦៥,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង២៥,៥%ធៀបនឹងខែមុននិងកើនឡើង៧៤,១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះ មានអតិរេកចំនួន **៤៧១,៩** ប៊ីលានរៀល (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៤–២០១៦

(ប៊ីលានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែឧសភាឆ្នាំ២០១៦មានលក្ខណៈដូចខាងក្រោម:

➢ រូបិយវត្ថុ $M_2$ មានចំនួន៥៣៣១៤ប៊ីលានរៀល កើនឡើង១%ធៀបនឹងខែមុន និងកើនឡើង១៨,៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការកើនឡើង $M_2$ ក្នុងខែនេះ ជារួម បណ្តាលមកពីការកើនឡើងនៃប្រាក់បញ្ញើចរន្ត៥,៣% ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ ៨,៨% និងប្រាក់បញ្ញើជារូបិយបណ្ណ១,២%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែឧសភាឆ្នាំ២០១៦



➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៥,៧% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៤,៣% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៦

| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១៦,៨% | ១៦,៦% | ១៥,៩% | ១៥,៨% | ១៥,៧% | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១២,២% | ១២,១% | ១១,៩% | ១១,៦% | ១១,២% | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែឧសភា២០១៦: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




---

➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៥៥៣៧លានដុល្លារ កើនឡើង០,៥%ធៀបនឹងខែមុន និងកើនឡើង២៣,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ***ក្នុងខែនេះមានចំនួន ១៧១៥៦ ប៊ីលានរៀលកើនឡើង ៤,៤%ធៀបនឹងខែមុន និងកើនឡើង២៥,៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| ផ្តល់ដោយ | ឧសភា២០១៦ | មេសា២០១៦ | ឧសភា២០១៥ |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ( ប៊ីលានរៀល ) | ៥៤៥០៤ | ៥៤០៧៣ | ៤២៤៨០ |
| ក្នុងនោះ ជារៀល | | | ៥៣៥ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ( ប៊ីលានរៀល ) | | ១១២៥១ | ៩៧២៩ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៥៥% | ៦,៥១% | ៦,៧៧% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦,១៦% | ១៦,៦៧% | ១៦,១៥% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤៣% | ៤,៤៣% | ៤,៣៥% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៦% | ១១,៤៧% | ១១,៥៤% |

## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងថាមពល

➡ក្នុងខែឧសភាឆ្នាំ២០១៦ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៤៧,៥ពាន់តោនកើនឡើង២%ធៀបនឹងខែមុន និងកើនឡើង៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៥៩៧,៩២GWHមានការកើនឡើង២%ធៀបនឹងខែមុន និងកើនឡើង១៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន៦៧,០២GWHមានការកើនឡើង៣៦%ធៀបនឹងខែមុន និងកើនឡើង១៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន២៥២,៧៣GWHមានការថយចុះ៧%ធៀបនឹងខែមុន និងមានការថយចុះ៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៥៧១,២លានដុល្លារមានការកើនឡើង១៥%ធៀបនឹងខែមុន និងកើនឡើង១៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន –ឧសភា២០១៦ | ចំនួន–មេសា២០១៦ | ចំនួន–ឧសភា២០១៥ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ១០ | ១១ | ២១ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៥១១ | ១៥០១ | ១៣៦៩ |
| ▪ ឧស្សាហកម្មធុនតូចនិងសិប្បកម្ម(បើកថ្មី) | | ៦ | ៣០ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | | ១០ | ២២ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១៥៣២,៥ពាន់ម$^2$ថយចុះ៦៧%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១០៩៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង៨៣២,២លានដុល្លារថយចុះ៨០%ធៀបនឹងខែមុន និងកើនឡើង១៩៩៥%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម$^2$ –ឧសភា២០១៦ | ពាន់ម$^2$ –មេសា២០១៦ | ពាន់ម$^2$ –ឧសភា២០១៥ |
|---|---|---|---|
| ▪ លំនៅឋាន | ៧៧៥ | ១៣៨៥,៣ | ៦១,៣ |
| ▪ ឧស្សាហកម្ម | ១៩២,៩ | ៥៣៨,៣ | ២២,៥ |
| ▪ពាណិជ្ជកម្ម | ៤៣៨ | ២៦៤៥,៨ | ២៦,៩ |
| ▪ ទេសចរណ៍ | ១២២,៦ | ២១,៧ | ១៦,៩ |
| ▪ផ្សេងៗ | ០ | ២,៨ | ០,៧ |
| អនុញ្ញាតសរុប | ១៥៣២,៥ | ៤៥៩៤ | ១២៣,៣ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅដ្ឋាន៥០,៦% និងពាណិជ្ជកម្ម២៨,៦% នៃផ្ទៃក្រឡាសរុប។

## ➢ការងារ

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–ឧសភា ២០១៦ | នាក់–មេសា ២០១៦ | នាក់–ឧសភា ២០១៥ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរ និងការងារ ) | ៩៥៨ | ៤៦៣ | ៩៥៨ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៤៧៨០ | ១២១៩៦ | ៤៤៣០ |
| អ្នកទទួលបានការងារក្នុងប្រទេស | ២១៤២ | ៨៦៤៣ | ១៧៩២ |
| អ្នកទទួលបានការងារក្រៅប្រទេស | ២៦២៨ | ៣៥៥៣ | ២៦៣៨ |

## ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | ឧសភា២០១៦ | មេសា២០១៦ | ឧសភា២០១៥ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ២៣,៧ | ៧៩០,៧ | ១៨៣,៩ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០ | ១៧,៧ | ៧៤,៥ |
| វិស័យឧស្សាហកម្ម (ក្នុងរង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ២១,១ (១៤,២) | ៥៤២,៣ (១) | ១០៦,៩ (១៨,៩) |
| វិស័យទេសចរណ៍ | ២,៦ | ១៩,៨ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ២១១ | ២,៥ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៦ | ១៩ | ១៨ |
| បង្កើតការងារ (ពាន់នាក់) | ៥ | ១៤,៦ | ១៤,៦ |

## ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន–ឧសភា ២០១៦ | ចំនួន–មេសា ២០១៦ | ចំនួន–ឧសភា២០១៥ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | | | ៣០៨ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | | | ២ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៤៩៩ | ៧០៥ | ៨៧ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៧៦៦,៩ពាន់តោនថយចុះ៩%ធៀបនឹងខែមុន និងថយចុះ៤%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:-៣% | (+១៥%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:-៤០% | (-៥៥%) |
| ▪ កំពង់ផែកំពង់សោម:-៩% | (-២%) | ▪ កំពង់ផែឧកញ៉ាម៉ុង: -៧% | (-២១%) |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៣,៧ | -៣% | ៣៩% |
| ក្នុងនោះទទួល | ២,១ | ១% | ៣១% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៨២,៧ | -១៤% | ១១% |
| ក្នុងនោះទទួល | ៤៥,៧ | -៥% | ២៧% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២៧៨៤,១ | ៦% | -១៧% |
| ក្នុងនោះហៅចូល | ៨៤០,៩ | ៥% | -១២% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៩០២០,២ | -១២% | -២៧% |
| ក្នុងនោះហៅចូល | ៨៩៦៣ | -១២% | -២៧% |

## ➢ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១២,៣ | -៩% | ៣៩% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២៦ | -១៨% | -១៣% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៤០៦,១ | -៩% | ៥% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១២៧,៣ | -៥% | ១៨% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៣២០,៦ | -១៣% | ២% |
| ✓ តាមផ្លូវអាកាស | ១៦៥,៣ | -១០% | ៣% |
| ✓ តាមផ្លូវគោក និងទឹក | ១៥៥,៣ | -១៦% | ១% |

## ៥) ស្ថានភាពពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែឧសភាមានចំនួន ៤៤៥៧,៦ប៊ីលានរៀល (ស្មើនឹង ១១១៤,៤លានដុល្លារ ស.រ.អា.)កើនឡើង៧,៤%ធៀបនឹងខែមុនប៉ុន្តែកើនឡើង២,៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -១៦,៥% | +១៦% | រថយន្តសរុប (បី.ល.រ) | +៩,៦% | -៦,៣% |
| ប្រេងម៉ាស៊ូត | -២០,១% | -១,៨% | រថយន្តសរុប (គ្រឿង) | +១៩,៦% | +១១,៦% |
| ឧស្ម័ន | +៤,២% | +៤៣,៥% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | 0% | -២៦,៥% |
| អគ្គិសនីនាំចូល | +៨,០% | +១៨,០% | ម៉ូតូ (គ្រឿង) | -៣៩,៤% | -១០,៧% |
| ដែកសំណង់ | +២១,៧% | +៨៤,៨% | អង្ករ | -៤៨,៦% | +៤២,៥% |
| ស៊ីម៉ង់ត៍ | +១៧,៤% | -១៩,៧% | ផ្លែឈើនិងបន្លែ | +២២,៩% | +៩,៩% |
| គ្រឿងអេឡិចត្រូនិក | -៣៧,២% | -៣៩,៣% | ជីនិងថ្នាំកសិកម្ម | +៧៥,៥% | -២៧,៣% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិ | +១៤,៤% | +៣,៣% |

➡ **ការនាំចេញ** ខែឧសភាឆ្នាំ២០១៦ មានចំនួន**៣០៣៥,១**ប៊ីលានរៀល ស្មើនឹង**៧៥៨,៨**លានដុល្លារ ស.រ.អា. (**៦៨**% នៃការនាំចូល)កើនឡើង៩,១%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៤,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៨៨,២% | -២០,២% | ផលិតផលនេសាទ | -១៥,៤% | -២៣,៣% |
| វាយនភណ្ឌនិងស្បែកជើង | +៧,១% | +៣,៥% | កៅស៊ូ | +៥១,៧% | +៤០,៧% |
| អង្ករ | -២៦,៧% | -២៣,៩% | | | |

➡ក្នុងខែឧសភានេះជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ១៤២២,៥ប៊ីលានរៀលស្មើនឹង៣៥៥,៦លានដុល្លារ ស.រ.អា.។

## ៦) ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែឧសភាឆ្នាំ២០១៦នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃត្រីស្រស់ | +០,៣% | +១០,២% | — |
| ២ | ថ្លៃបន្លែ | +១,៤% | +១០,៣% | — |
| ៣ | ទុនវិនិយោគអនុញ្ញាតដោយ ក.អ.ក. | -៩៧,០% | -៨៧,១% | — |

## ៧) សេចក្តីសន្និដ្ឋាន

១) ម្ហូបអាហារជាក្រុមទំនិញដែលមានការឡើងថ្លៃខ្ពស់ជាងគេក្នុងចំណោមទំនិញប្រើប្រាស់ ដែលក្នុងនោះគួរកត់សម្គាល់លើការឡើងថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុននៃសាច់ ត្រី និងបន្លែ ។ ផលិតកម្មកសិកម្មនៅកម្ពុជាបច្ចុប្បន្នដូចជាដំណាំ និងការចិញ្ចឹមសត្វមិនទាន់ផ្គាប់តម្រូវការបានគ្រប់គ្រាន់។ វិស័យនេះត្រូវការការពង្រីកខ្នាតផលិតកម្ម និងទំនើបកម្មនៃការផលិត ដែលតម្រូវ ការឲ្យមានការវិនិយោគទ្រង់ទ្រាយធំលើហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ដូចជាប្រព័ន្ធធារាសាស្ត្រ និងកសិដ្ឋានចិញ្ចឹមសត្វ។

២) យោងតាមតួលេខនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ទុនវិនិយោគបរទេសដែលអនុញ្ញាតមានការថយចុះគួរឲ្យចាប់អារម្មណ៍។ ក្នុងរយៈពេល ៥ខែ ដើមឆ្នាំ២០១៦ ការអនុញ្ញាតទុនវិនិយោគមានចំនួន ១ ៨២២ លានដុល្លារ ស.រ.អា រីឯក្នុងរយៈពេលដូចគ្នា ឆ្នាំ២០១៥ សូចនាករនេះមានចំនួន ៣ ១៥៦ លានដុល្លារ ស.រ.អា។ ទន្ទឹមនឹងនោះ ចំនួនរោងចក្រថ្មីដែលចុះបញ្ជីនៅក្រសួងឧស្សាហកម្មក៏មានការថយចុះគួរឲ្យកត់សម្គាល់។ ដូច្នេះការទាក់ទាញវិនិយោគបរទេសជាកិច្ចការចម្បង សម្រាប់សេដ្ឋកិច្ចកម្ពុជានារយៈពេលខ្លី និងមធ្យមខាងមុខ។



## III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១៦

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៦/១៦ ម៉ោង១៦:៣០នាទី | ចូលរួមប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានគ្រប់ស្រុក ក្រុង ទូទាំងខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ នៅគេហដ្ឋាន ឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី។ |
| ២ | ០៣/០៦/១៦ ម៉ោង១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយលោក Alexandre Lapeyre នាយកគ្រប់គ្រងផែនការ និងបច្ចេកទេស នៃអាកាសយានដ្ឋានអន្តរជាតិនៅក្នុងប្រទេសកម្ពុជា នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៧/០៦/១៦ ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង និងក្រុមការងារបច្ចេកទេសដោះស្រាយបញ្ហាសំណង់អនាធិបតេយ្យនៅជាប់របងជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដើម្បីពិនិត្យ និងពិភាក្សាលើការងារដោះស្រាយផលប៉ះពាល់គម្រោងពង្រីងតំបន់សុវត្ថិភាព និងសន្តិសុខនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៨/០៦/១៦ ម៉ោង១៥:៣០នាទី | ទទួលជួបប្រជុំពិភាក្សាការងារជាមួយលោក CHUNG DAE YONG ទីប្រឹក្សាស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ប្រចាំនៅប្រទេសកម្ពុជា នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៩/០៦/១៦ ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ជាមួយក្រុមហ៊ុន SCA និងក្រុមហ៊ុន ARCHETYPE ដើម្បីពិភាក្សា និងពិនិត្យលើប្លង់ពង្រីកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១៣/០៦/១៦ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវមជ្ឈមណ្ឌលកម្ពុជាដើម្បីស្រាវជ្រាវផ្លូវសូត្រសមុទ្រ របស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៧ | ១៤/០៦/១៦ ម៉ោង១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីពិសាអាហារស្រាយបួស ខែរ៉ាម៉ាឌន ឆ្នាំ២០១៦ នៃសាសនាឥស្លាមកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | **១៥/០៦/១៦ ម៉ោង១១:៣០នាទី** | ចូលរួមជួបពិភាក្សាការងារជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅគេហដ្ឋាន ឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី។ |
| ៩ | **១៦/០៦/១៦ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាសអគារ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** (អគារទី៣) និងខួបលើកទី៧០ឆ្នាំ នៃការបង្កើតសាកលវិទ្យាល័យវិទ្យាសាស្រ្តសុខាភិបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅសាកលវិទ្យាល័យវិទ្យាសាស្រ្តសុខាភិបាល។ |
| ១០ | **១៩/០៦/១៦ ម៉ោង០៨:៣០នាទី** | តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងកម្មវិធី YOGA អន្តរជាតិ នៅពហុកីឡាដ្ឋានជាតិអូឡាំពិក។ |
| ១១ | **២០/០៦/១៦ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទវគ្គប្រគល់សញ្ញាបត្រដល់សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ឧត្តមគតិជាតិ សិស្សមន្ត្រីក្រមការ ជំនាន់សាមគ្គីជាតិ និងវិញ្ញាបនបត្រជូនកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ មន្ត្រីមធ្យមឆ្នាំ២០១៥ សិក្ខាកាមមន្ត្រី នៃក្រសួងបរិស្ថាន និងសិក្ខាកាមថ្នាក់ដឹកនាំជាស្រ្តី ព្រមទាំងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០១៦ របស់សាលាភូមិន្ទរដ្ឋបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១២ | **២១/០៦/១៦ ម៉ោង០៩:០០នាទី** | អញ្ជើញជាអធិបតី ក្នុងកិច្ចប្រជុំផ្សព្វផ្សាយការសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីបញ្ហាសំណង់ស្ថិតក្នុងតំបន់សន្តិសុខ និងតំបន់សុវត្ថិភាពជុំវិញអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅសាលាខណ្ឌពោធិ៍សែនជ័យ។ |
| ១៣ | **២២/០៦/១៦ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីទទួលជ័យលាភី "កម្ពុជាជាគោលដៅទេសចរណ៍ល្អបំផុតលើពិភពលោកឆ្នាំ២០១៦ The World Best Tourist Destination For 2016" និងប្រកាស "កម្ពុជាជាគោលដៅវប្បធម៌ពេញនិយមក្នុងឆ្នាំ២០១៦" អមជាមួយការប្រកាសជាផ្លូវការនូវចលនាប្រឡងប្រណាំង "បដិសណ្ឋារ កិច្ចល្អ" លើកទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៤ | **២៣/០៦/១៦ ម៉ោង០៨:៣០នាទី** | អញ្ជើញចុះចែកថ្នាំពេទ្យជូនប្រជាពលរដ្ឋក្នុងឃុំក្តាញ់ និងពិនិត្យការដ្ឋានជីកស្រះក្នុងឃុំតាំងយ៉ាប និងភូមិក្បៀម ឃុំក្តាញ់ នៃស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ១៥ | **២៤/០៦/១៦ ម៉ោង១៨:០០នាទី** | ចូលរួមក្នុងពិធីជប់លៀងជាមួយឯកឧត្តមឯកអគ្គរដ្ឋទូតបារាំង នៅស្ថានទូត។ |
| ១៦ | **២៧/០៦/១៦ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងាររៀបចំបញ្ញត្តិ ស្តីពីការអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដើម្បីពិនិត្យលើសេចក្តីសម្រេចស្តីពីការបង្កើតក្រុមវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | **២៨/០៦/១៦ ម៉ោង១៥:៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយលោកជំទាវ តាល់ ណៃអ៉ីម នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៨ | **២៨/០៦/១៦ ម៉ោង១៨:៣០នាទី** | ចូលរួមពិធីជប់លៀង ក្នុងឱកាសឯកឧត្តមឯកអគ្គរដ្ឋទូតអាឡឺម៉ង់ជម្រាបលា នៅស្ថានទូត។ |
| ១៩ | **២៩/០៦/១៦ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរខួបលើកទី៦៥ឆ្នាំ នៃថ្ងៃបង្កើតស្ថាប័នគយ និងរដ្ឋាករកម្ពុជា (២៩/មិថុនា/១៩៥១-២៩/មិថុនា/២០១៦) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។ |
| ២០ | **៣០/០៦/១៦ ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២១ | **៣០/០៦/១៦ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែឧសភា ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ទេសរដ្ឋមន្ត្រី យឹម ណុលឡា ចុះចែកថ្នាំពេទ្យ ជូនស្ត្រីជាង ៣០០នាក់ នៅស្រុកព្រៃកប្បាស



ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងសហការី ក្នុងនោះដែរក៏មានវត្តមានឯកឧត្តម **ខ៉ាន់ តិរុណា** អគ្គលេខាធិការនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

មានប្រសាសន៍ក្នុងឱកាសនោះ **ឯកឧត្តម ទេសរដ្ឋមន្ត្រី** បានបញ្ជាក់ពីការយកចិត្តទុកដាក់ខ្ពស់ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់សុខុមាលភាព និងអាហារូបត្ថម្ភរបស់ប្រជាជនទូទៅ ក្នុងការកាត់បន្ថយអត្រាស្លាប់របស់មាតា ទារក និងកុមារ តាមរយៈការពង្រឹង និងពង្រីក សេវាសុខាភិបាលប្រកបដោយគុណភាព ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ។

ព្រមជាមួយគ្នានោះ **ឯកឧត្តម ទេសរដ្ឋមន្ត្រី** ក៏បានលើកឡើងពីព្រះរាជាណាចក្រកម្ពុជា ទទួលបានពានរង្វាន់ «ប្រទេសកម្ពុជា ជាគោលដៅទេសចរណ៍ល្អបំផុតសម្រាប់ឆ្នាំ២០១៦» និង «កម្ពុជាជាគោលដៅទេសចរណ៍វប្បធម៌ពេញនិយម ក្នុងឆ្នាំ២០១៦» ពីក្រុមប្រឹក្សាភិបាលទេសចរណ៍ និងពាណិជ្ជកម្មនៃសហភាពអឺរ៉ុប និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ទទួលបានជ័យលាភីពានរង្វាន់ជា « សមាជិកកិត្តិយស» នៃបណ្ឌិតសភាទេសចរណ៍អឺរ៉ុប។





ប្រជាពលរដ្ឋក្នុងអង្គប្រជុំទាំងមូល អបអរសាទររំភើបរីករាយ ចំពោះព័ត៌មានខាងលើនេះ ដែលឲ្យប្រទេសកម្ពុជាល្បីរន្ទឺនៅលើឆាកអន្តរជាតិ។ នៅក្នុងពិធីចែកថ្នាំពេទ្យជូនប្រជាពលរដ្ឋនៅទីនោះ ក៏មានការព្យាបាលជំងឺជូនប្រជាជនពីសំណាក់លោកគ្រូពេទ្យផងដែរ។



ក្នុងថ្ងៃដដែលនោះ **ឯកឧត្តម ទេសរដ្ឋមន្ត្រី** និងក្រុមការងារអមដំណើរដោយលោកស្រី **នូ សុវណ្ណនី** អភិបាលរងខេត្តតាកែវ បានចុះត្រួតពិនិត្យការងារ ស្តារស្រះទឹកនៅភូមិក្បូម ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ ស្រះនេះមានបណ្តោយ ៦០ម៉ែត្រ ទទឹង ៥០ម៉ែត្រ និងជម្រៅ ៤ម៉ែត្រ ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចតេជោ **ហ៊ុន សែន** និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ស្របតាមសំណូមពររបស់ប្រជាជន ៣១៥គ្រួសារ។ ស្រះទឹកនេះ បានចាប់ផ្តើមបើកការដ្ឋានកាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦កន្លងទៅនេះ ដែលនឹងត្រូវបញ្ចប់ជាស្ថាពរនៅសប្តាហ៍ក្រោយ។

បន្ទាប់មកទៀត **ឯកឧត្តម ទេសរដ្ឋមន្ត្រី** និងក្រុមការងារ បានចុះមើលស្រះ នៅក្នុងឃុំតាំងយ៉ាប ដែលកំពុងស្តារ នឹងត្រូវបញ្ចប់រួចរាល់ក្នុងពេលឆាប់ៗនេះ៕



រូបភាពនៃកិច្ចប្រជុំស្ដីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៦



# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in